**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ :......០៦៨/២៦......................ក.ប/វ.ស.ក.ស.ក.៣)

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកវគ្គបណ្តុះបណ្តាលសញ្ញាបត្រវិជ្ជាជីវៈអាជ្ញាកណ្តាលការងារ ជំនាន់ទី១

វិទ្យាស្ថានជាតិការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជនជ្រាបថា វិទ្យាស្ថាននឹងបើកវគ្គបណ្តុះបណ្តាលសញ្ញាបត្រវិជ្ជាជីវៈអាជ្ញាកណ្តាលការងារ ជំនាន់ទី១ ចំនួន ៦០នាក់ សម្រាប់ឆ្នាំសិក្សា ២០២៦-២០២៧។ វគ្គនេះ ត្រូវបានរៀបចំឡើងសម្រាប់សាធារណជនដែលមានបំណងចង់ក្លាយជាសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

បេក្ខជនដែលមានបំណងចុះឈ្មោះចូលរៀនត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ញាបត្របរិញ្ញាបត្រនីតិសាស្ត្រ ឬសញ្ញាបត្រសមមូល
- មានបទពិសោធការងារពាក់ព័ន្ធវិស័យច្បាប់ ឬវិស័យការងារ ឬការដោះស្រាយវិវាទការងារ។

សម្រាប់ការចុះឈ្មោះចូលរៀននិងព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈលេខទូរសព្ទ(តេឡេក្រាម)៖ ០១២ ៦៦២ ៧២៩/០៧៧ ៨៦៨ ៣៨៨/០១២ ៣៨៨ ៨៣២។

***កាលបរិច្ឆេទទទួលពាក្យចុះឈ្មោះចូលរៀន ចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦។***

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ១២ កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០២៦

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩